WISe
Wraparound ជាមួយ
សេវាកម្មបន្ទាន់



គ្រួសារ

# វិធីថ្មីដើម្បីបំពេញតម្រូវការកុមារដែលមានបញ្ហាសុខភាពផ្លូវចិត្តក្នុងរដ្ឋវ៉ាស៊ីនតោន លើ Apple Health Medicaid ។

## តើអ្វីជា WISe?

WISe គឺជាសេវាកម្មស្ម័គ្រចិត្តដែលយកវិធីក្រុមដើម្បីបំពេញតម្រូវការកូនរបស់អ្នក ។ វាផ្តល់សេវាកម្មសុខភាពផ្លូវចិត្តបន្ទាន់ដើម្បីជួយកូនរបស់អ្នក និងជួយគ្រួសាររបស់អ្នកខិតខិតគោលដៅរបស់អ្នក ។

### ការផ្តោតនៃ WISe គឺ ៖

- ដើម្បីផ្តល់សេវាកម្មសុខភាពផ្លូវចិត្តបន្ទាន់ដែលបានរចនាដើម្បីជួយកូន និងគ្រួសាររបស់អ្នកក្នុងការសម្រេចបាននូវសុខុមាលភាព សុវត្ថិភាព និងដើម្បីពង្រឹងទំនាក់ទំនងនៅក្នុងសហគមន៍របស់អ្នក ។
- ដើម្បីបង្កើតគម្រោងថែទាំផ្ទាល់ខ្លួន ដែលផ្តែកលើចំណុចខ្លាំង និងតម្រូវការដែលគោរពវប្បធម៌ តម្លៃ បទដ្ឋាន និងចំណូលចិត្តរបស់គ្រួសារអ្នក ។ កូន និងគ្រួសាររបស់អ្នកដឹកនាំ និងបញ្ជាគម្រោងដោយប្រើក្រុម ។ សមាជិកក្រុមរាប់បញ្ចូលទាំងជំនួយធម្មជាតិ (ដូចជាគ្រួសារ មិត្តភក្តិ និង អ្នកដឹកនាំសាសនា) និងអ្នកជំនាញដែលធ្វើការជាមួយគ្រួសារអ្នក (ដូចជាអ្នកប្រឹក្សា សាលារៀន CPS និងមន្ត្រីហាត់ការ) ។
- ដើម្បីផ្តល់សេវាកម្ម និងជំនួយក្នុងទីតាំង និងពេលវេលាដែលល្អបំផុតសម្រាប់កូន និងគ្រួសាររបស់អ្នក (ដែលរាប់បញ្ចូលទាំងក្នុងផ្ទះរបស់អ្នក ឬទីតាំងសាធារណៈនៃជម្រើស និងនៅពេលល្ងាច ឬចុងសប្តាហ៍) ។
- ដើម្បីស្គាល់ ឬផ្តល់ធនធាន និងជំនួយដល់កូន និងគ្រួសាររបស់អ្នក ។
- ដើម្បីផ្តល់ជំនួយក្នុងពេលមានវិបត្តិ ។ អ្នកអាចចូលដល់សេវាកម្មវិបត្តិសម្រាប់កូនរបស់អ្នកគ្រប់ពេល 365 ថ្ងៃក្នុងមួយឆ្នាំ ។ កូនរបស់អ្នកនឹងទទួល សេវាកម្មពីបុគ្គលដែលដឹងពីតម្រូវការ និងកាលៈទេសៈរបស់កូន និងគ្រួសារអ្នក រួមទាំងគម្រោងវិបត្តិបច្ចុប្បន្នរបស់ពួកគេ ពេលដែលចាំបាច់ វារាប់បញ្ចូលទាំងអន្តរាគមន៍ផ្ទាល់នៅទីតាំងដែលវិបត្តិកើតឡើង ។

### គោលការណ៍ WISe ៖

**WISe ឲ្យតម្លៃជំនួយនោះដែលធ្វើឲ្យលទ្ធផលល្អប្រសើរសម្រាប់កុមារ៖**

1. សម្លេង និងជម្រើសរបស់គ្រួសារ និងយុវជន
2. ផ្តែកលើក្រុម
3. ជំនួយធម្មជាតិ
4. ការសហការ
5. ផ្អែកលើ ផ្ទះ និងសហគមន៍
6. ទាក់ទងផ្អែកវប្បធម៌
7. ធ្វើឲ្យទៅជារបស់បុគ្គល
8. ផ្អែកលើចំណុចខ្លាំង
9. ផ្អែកលើលទ្ធផល
10. គ្មានលក្ខខណ្ឌ

## តើនរណាខ្លះអាចទទួលបាន WISe?

WISe មានសម្រាប់កុមារ/យុវជនមានសិទ្ធិទទួលបាន Medicaid ពីចាប់កំណើតដល់អាយុ 21 ឆ្នាំដែលបំពេញការទទួលបានបទដ្ឋានការថែទាំ (បទដ្ឋានដែលប្រើដោយទីភ្នាក់ងារសុខភាពផ្លូវចិត្តក្នុងការទទួលបានកម្រិតត្រឹមត្រូវនៃសេវាកម្មដល់បុគ្គលម្នាក់ៗ) ។

## តើពេលណាដែលមានប្រយោជន៍សម្រាប់ខ្ញុំក្នុងការចូលប្រើ WISe?

អ្នកអាចបញ្ជូនកូនអ្នកសម្រាប់ការពិនិត្យ WISe **គ្រប់ពេល** ឪពុកម្តាយអាចផ្តួចផ្តើមការព្យាបាល ប៉ុន្តែលើសពីអាយុ 13 ឆ្នាំ កុមារត្រូវតែយល់ព្រមនឹងសេវាកម្ម ។ អ្នកគួរតែពិចារណាបញ្ជូនកូនអ្នកសម្រាប់ការពិនិត្យ WISe បើគាត់ជា ៖

- អ្នកប្រើប្រាស់ខ្សែវិបត្តិ ឬបន្ទប់សង្គ្រោះបន្ទាន់ញឹកញ៉ាប់ ដោយសារការព្រួយបារម្ភអំពីសុខភាពផ្លូវចិត្តរបស់កូនអ្នក ។
- ការជួបប្រទះអាកប្បកិរិយាដែលពិបាកយល់ (ដូចជាការរត់ចេញ ឬការចាប់ខ្លួនញឹកញ៉ាប់ដោយសារសុខភាពផ្លូវចិត្ត) ដែលជាបញ្ហាដល់អ្នក អ្នកផ្តល់ការថែទាំផ្សេងទៀត ឬអ្នកព្យាបាល/គ្រូពេទ្យ និងសេវាកម្មប្រពៃណីតែមួយមិនអាចជួយបាន ។
- ការបង្ហាញការកើនឡើងហានិភ័យនៃគ្រោះថ្នាក់ដល់ខ្លួនពួកគេ ឬអ្នកដទៃ ។
- ត្រូវការវិធីសាស្ត្របន្ទាន់ និងផ្ទាល់ខ្លួនដើម្បីការព្យាបាល ។
- ត្រូវការវិធីសាស្ត្រងាយស្រួលបត់បែន និងការទាក់ទង ។
- បានចូលរួមក្នុងប្រព័ន្ធច្រើន (ឧទាហរណ៍ សុខភាពផ្លូវចិត្ត សុខុមាលភាពកុមារ (CPS) យុត្តិធម៌អនីតិជន សេវាកម្មការអភិវឌ្ឍពិការភាព និង/ឬការព្យាបាល វិបត្តិប្រើសារធាតុញៀន) និងប្រព័ន្ធកំពុងពិបាកជំតស៊ូគាំទ្រកូនរបស់អ្នកជាមួយគ្នា ។
- ក្នុងការអប់រំពិសេស និង/ឬមានគម្រោង 504 ជាមួយការព្យួរនៅសាលារៀនជាច្រើនដងសម្រាប់សុខភាពផ្លូវចិត្ត និង/ឬបញ្ហាអាកប្បកិរិយា ។

Washington State
Department of Social
& Health Services
Transforming lives

DSHS 22-1594 CA (Rev. 8/16) Cambodian

## តើ WISe នឹងមានក្នុងសហគមន៍ខ្ញុំនៅពេលណា?

WISe កំពុងពង្រីកខ្លួនចេញពីរដ្ឋវ៉ាស៊ីនតោនដល់ខែមិថុនា ឆ្នាំ 2018 ដូច្នេះវាអាចមិនទាន់មានក្នុងផ្នែកនៃរដ្ឋរបស់អ្នក ។ ការបញ្ជូនសម្រាប់ការពិនិត្យ WISe អាចត្រូវបានធ្វើឡើងគ្រប់ពេលក្នុងមណ្ឌលដែលបានអនុវត្ត WISe ។ ដើម្បីដឹងថា បើ WISe មាននៅកន្លែងដែលអ្នករស់នៅ និងទាក់ទងនរណា សូមចូល ៖ [www.dshs.wa.gov/dbhr/cbh-wise.shtml](www.dshs.wa.gov/dbhr/cbh-wise.shtml) និងចុចលើឯកសារ "បញ្ជីទាក់ទងសម្រាប់បញ្ជូន WISe តាមខោនធី" ។

បើ WISe មិនទាន់មានក្នុងតំបន់នៃរដ្ឋរបស់អ្នក ហើយអ្នកជឿជាក់ថាកូនរបស់អ្នកនឹងទទួលផលប្រយោជន៍ពីសេវាកម្មសុខភាពផ្លូវចិត្ត ប្រើព័ត៌មានទំនាក់ទំនងដែលរកបាននៅគេហទំព័រ ៖ [https://www.dshs.wa.gov/bha/division-behavioral-health-and-recovery/mental-health-services-and-information](https://www.dshs.wa.gov/bha/division-behavioral-health-and-recovery/mental-health-services-and-information) ដើម្បីធ្វើការបញ្ជូន ឬទូរស័ព្ទទៅខ្សែជំនួយស្តារឡើងវិញ តាមលេខទូរស័ព្ទឥតគិតថ្លៃ 866-789-1511 ។

## តើមានអ្វីកើតឡើងពេលដែលខ្ញុំធ្វើការបញ្ជូន?

ការបញ្ជូនទាំងអស់គួរតែឲ្យលទ្ធផលជាការពិនិត្យ WISe ។ ការពិនិត្យ WISe ត្រូវតែត្រូវបានផ្តល់ជូនក្នុង 10 ថ្ងៃធ្វើការនៃការទទួលការបញ្ជូន ។ ការពិនិត្យ WISe ទាំងអស់រាប់បញ្ចូលទាំង ៖

- ការប្រមូលព័ត៌មាន ដើម្បីបំពេញការពិនិត្យតម្រូវការ និងចំណុចខ្លាំងវ័យជំទង់របស់កុមារ ដែលមាន 26 សំណួរ ។ ការពិនិត្យនេះនឹងកំណត់ថាតើកូនអ្នកអាចទទួលផលប្រយោជន៍ពីកម្រិតការថែទាំដែល WISe ផ្តល់ឲ្យ ។ ឧបករណ៍ពិនិត្យនេះអាចត្រូវបានបំពេញតាមទូរស័ព្ទ ឬដោយផ្ទាល់ ។
- ពេលដែលឧបករណ៍ពិនិត្យបង្ហាញថា WISe មានសក្តានុពលផ្តល់ផលប្រយោជន៍ដល់កូនអ្នក កូនអ្នកត្រូវបានបញ្ជូនទៅទីភ្នាក់ងារ WISe ដែលការវាយតម្លៃឲ្យចូលអាចត្រូវបានបំពេញ ។ ទីភ្នាក់ងារអ្នកផ្តល់សេវាកម្ម WISe ក៏ងចាត់តាំងក្រុមថ្មីដល់កូនរបស់អ្នក ហើយការថែទាំទាំងអស់នឹងត្រូវបានធ្វើតាមរយៈទីភ្នាក់ងារ/ក្រុមនោះ ។
- បើវាត្រូវបានកំណត់ថាកូនរបស់អ្នកដូចជាមិនបានបំពេញកម្រិតការថែទាំ ដែល WISe ផ្តល់ឲ្យ កូនរបស់អ្នក នឹងត្រូវបានបញ្ជូនទៅសេវាកម្មសុខភាពផ្លូវចិត្តសាកសមផ្សេងទៀត ដើម្បីលើកឡើងពីតម្រូវការរបស់គាត់ ។



គ្រួសារនីមួយៗខុសៗគ្នា ។
ដំណោះស្រាយនីមួយៗគឺផ្ទាល់ខ្លួន ។

## ចង់ចូលរួមទេ?

សម្លេងរបស់អ្នកអាចជួយធ្វើឲ្យសេវាកម្មសម្រាប់កុមារ និងយុវវ័យប្រសើរឡើង ។ គ្រួសារ យុវជន ប្រព័ន្ធដៃគូតុម្ពូល (FYSPRTs) គឺជាផ្នែកដ៏សំខាន់នៃរចនាសម្ព័ន្ធគ្រប់គ្រងដែលកំពុងធ្វើការដើម្បីធ្វើឲ្យប្រព័ន្ធសុខភាពអាកប្បកិរិយារបស់កុមារប្រសើរឡើង ដែលរាប់បញ្ចូលទាំង WISe ។ សិក្សាបន្ថែមនៅទីនេះ ៖ [FYSPRT.com](FYSPRT.com)

***Washington's Wraparound ជាមួយសេវាកម្មបន្ទាន់ (WISe)**
**ទិដ្ឋភាពទូទៅនៃបណ្តឹង T.R. et al. v. Kevin Quigley និង Dorothy Teeter**

ក្នុងខែវិច្ឆិកា ឆ្នាំ 2009 បណ្តឹង Medicaid ត្រូវបានដាក់ (ពីមុនត្រូវបានហៅ T.R. v. Dreyfus) ប្រឆាំងនឹងក្រសួងសេវាកម្មសង្គម និងសុខាភិបាល និងអាជ្ញាធរថែទាំសុខភាពអំពីសេវាកម្មសុខភាពផ្លូវចិត្តបន្ទាន់សម្រាប់កុមារ និងយុវវ័យ ។ បណ្តឹងផ្អែកលើច្បាប់ EPSDT (ការពិនិត្យតំបូង និងរយៈពេលកំណត់ រោគវិនិច្ឆ័យ និងការព្យាបាល) សហព័ន្ធដែលតម្រូវឲ្យរដ្ឋផ្តល់សេវាកម្មសុខភាពផ្លូវចិត្ត និងការព្យាបាលដល់កុមារដែលត្រូវការពួកវា ទោះបីជាសេវាកម្មមិនត្រូវបានផ្តល់ជូនពីមុនមក ។ ក្រោយពីការចរចាប៉ុន្មានឆ្នាំមក ភាគីទាំងពីរបានយល់ព្រមលើគម្រោងដែលពួកគេជឿជាក់ថានឹងធ្វើឲ្យពួកគេគោរពតាមច្បាប់ និងការនៃតែសំខាន់ ធ្វើការសម្រាប់យុវជន និងគ្រួសារក្នុងរដ្ឋវ៉ាស៊ីនតោន ។ តុលាការសហព័ន្ធបានយល់ស្របលើការព្រមព្រៀងដោះស្រាយនៅថ្ងៃទី 19 ខែធ្នូ ឆ្នាំ 2013 ។ គោលដៅនៃការព្រមព្រៀងដោះស្រាយ គឺ ដើម្បីបង្កើតប្រព័ន្ធដែលផ្តល់សេវាកម្មសុខភាពផ្លូវចិត្តបន្ទាន់ក្នុងផ្ទះ និងសហគមន៍ ដែលដំណើរការ - សម្រាប់យុវជនដែលមានសិទ្ធិទទួលបាន Medicaid ដល់អាយុ 21 ឆ្នាំ ។